**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ: លោក ខៀវ សំផន

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: **ខ្មែរ**

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 06-Feb-2012, 15:34
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ អ.ជ.ស.ដ: **សាធារណៈ/Public**

ប្រភេទនៃចំណាត់:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើសុំឲ្យមានការដាក់បង្ហាញឯកសារពីសម័យនោះ ជាសំណៅដើម នៅក្នុងសវនាការ**

---

ដាក់ដោយ៖

**សហមេធាវីការពារក្តីលោក ខៀវ សំផន**

លោក គង់ សំអុន

លោក Arthur VERCKEN

លោក Jacques VERGES

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Shéhérazade BOUARFA

កញ្ញា Clémence WITT

កញ្ញា អ៊ូច ស្រីផាត

កញ្ញា Mathilde CHIFFERT

ផ្ញើជូន៖

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យូរ ឧត្តរា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្តីទាំងអស់**

លោក Samy SALAMON

# សូមគោរពអង្គជំនុំជម្រះសាលាដំបូង

## I. អង្គហេតុ និងការបង្ហាញអំពីអង្គហេតុ

១. នៅថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចផ្ទាល់មាត់មួយស្តីអំពីឯកសារ។ នៅក្នុងសេចក្តីសម្រេចនេះ អង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ថា "*ឯកសារដើមគឺជាវិធីសាស្ត្រប្រសើរជាងគេនៃការយកមកបង្ហាញជាភស្តុតាង ហើយនិងត្រូវបានផ្តល់ទម្ងន់ច្រើនជាងឯកសារថតចម្លង*"[1]។

២. នៅថ្ងៃដដែលនេះ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសជូនដំណឹងអំពីការចូលមកបង្ហាញខ្លួននៅចំពោះមុខតុលាការ របស់លោក ឆាំង យុ ដែលជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam)[2]។

៣. លោក ឆាំង យុ បានមកបង្ហាញខ្លួននៅចំពោះមុខតុលាការ ចាប់ពីថ្ងៃពុធ ទី១ ខែកុម្ភៈ ឆ្នាំ២០១២។ គាត់បានបញ្ជាក់អះអាងថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានកំណត់នូវបេសកកម្មរបស់ខ្លួន មានជាអាទិ៍ការប្រមែប្រមូលចងក្រង និងថែរក្សាទុកនូវរាល់ឯកសារទាំងអស់ដែលមានទាក់ទងនឹងសម័យកាលនៃកម្ពុជាប្រជាធិបតេយ្យ[3]។ គឺអង្គការរបស់លោកដែលបានផ្តល់ជូនដល់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតនូវឯកសារភស្តុតាងស្ទើរតែទាំងអស់។ ប៉ុន្តែដូចដែលលោក ឆាំង យុ[4] បានទទួលស្គាល់ស្រាប់ សហព្រះរាជអាជ្ញា ក៏ដូចសហចៅក្រមស៊ើបអង្កេតមិនដែលស្នើសុំទាល់តែសោះទៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីអាចពិនិត្យមើលនូវឯកសារដើមសូម្បីតិចតួចក្នុងចំណោមឯកសាររាប់ពាន់ច្បាប់ ដែលឯកសារស្កេនឬឯកសារចម្លងចេញពីឯកសារថតចម្លងទាំងនោះត្រូវបានផ្តល់មកឱ្យខ្លួន។ ហើយនៅពេលបច្ចុប្បន្ននេះ ឯកសារស្កេន ឬឯកសារចម្លងចេញពីឯកសារថតចម្លងទាំងនោះបង្កើតបានជាឯកសារភាគច្រើនក្នុងសំណុំរឿងដែលបានដាក់ជូនតុលាការ។

---

[1] ប្រតិចារឹកសវនាការ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ ឯកសារតុលាការ E1/34.1 ទំព័រ ៩២ បន្ទាត់ ១-៤ [លេខទំព័រនិងលេខបន្ទាត់ក្នុងប្រតិចារឹកជាភាសាបារាំង]; ចម្លើយរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងផ្នែកខ្លះនៃឯកសារ E114, E114/1, E131/1/9, E131/6, E136 et E158, អនុស្សរណៈ ចុះថ្ងៃទី ៣១ ខែមករា ឆ្នាំ២០១២ ឯកសារ **E162** កថាខណ្ឌ ៥។

[2] ប្រតិចារឹកសវនាការ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ ឯកសារតុលាការ E1/34.1 ទំព័រ ៩៤ បន្ទាត់ ១៦-១៧ [លេខទំព័រនិងលេខបន្ទាត់ក្នុងប្រតិចារឹកជាភាសាបារាំង]។

[3] ប្រតិចារឹកសវនាការ ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១២ អត្ថបទប្រតិចារឹកព្រាង ទំព័រ ២៨ និង ៩១។

[4] ប្រតិចារឹកសវនាការ ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២ អត្ថបទប្រតិចារឹកព្រាង ទំព័រ ១៣ បន្ទាត់ ១៨-២០ [លេខទំព័រនិងលេខបន្ទាត់ក្នុងប្រតិចារឹកជាភាសាបារាំង]។

៤. ដោយហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងត្រូវស្ថិតនៅក្នុងស្ថានភាពដែលត្រូវចេញសេចក្ដីសម្រេចនាពេលអនាគតរបស់ខ្លួន ដោយសម្អាងលើឯកសារថតចម្លងដែលត្រូវបានផ្ដល់ឱ្យដោយអង្គការមួយដែលនាយករបស់អង្គការនេះបានទទួលស្គាល់នៅចំពោះមុខអង្គជំនុំជម្រះថា អង្គការរបស់ខ្លួនមិនដែលបានទទួលអាណត្តិជាផ្លូវការរបស់តុលាការណាមួយសោះ ក្នុងធ្វើការថែរក្សាទុកនូវធាតុផ្សំនៃភស្តុតាងឡើយ[5]។ ហើយអង្គការរបស់ខ្លួនមានភាពមិនច្បាស់លាស់ និងស្រពិចស្រពិលជាទីបំផុតទាក់ទងនឹងវិធីសាស្ត្រដែលបានយកមកប្រើប្រាស់ដោយសមាជិករបស់ខ្លួន ដើម្បីវាយតម្លៃអំពីយថាភូតនៃឯកសារដែលកាន់កាប់ដោយអង្គការខ្លួនតែមួយគត់។

៥. សម្រាប់ជាឧទាហរណ៍ យើងសូមរំឭកថា លោក ឆាំង យុ បានបញ្ជាក់ប្រាប់ថា ឯកសារទាំងឡាយដែលមានតែជាឯកសារថតចម្លងតែប៉ុណ្ណោះ ត្រូវបានចុះបញ្ជីដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងត្រូវបានចាត់ទុកថាជាឯកសារដើម ដោយយកលេសថា វាគឺជាឯកសារថតចម្លងតែមួយគត់ដែលគេអាចរកបាននៅក្នុងទឹកដីនៃប្រទេសកម្ពុជា[6]។ នៅចំពោះមុខតុលាការ លោក ឆាំង យុ បានបដិសេធមិនព្រមនិយាយថា តើឯកសារដែលរូបលោកចាត់ទុកថាជាឯកសារដើមនៃសម័យកាលនោះ[7]ស្ថិតនៅឯណាទេ។ ហើយលោកក៏មានភាពមិនច្បាស់លាស់ខ្លាំងផងដែរទាក់ទងនឹងវិធីសាស្ត្រដែលត្រូវបានប្រើប្រាស់ដោយសមាជិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីវាយតម្លៃលើយថាភូតនៃឯកសារសម័យនោះ។

៦. ទាក់ទងនឹងចំណុចចុងក្រោយនេះ លោក ឆាំង យុ បានបញ្ជាក់ប្រាប់តុលាការថា ឯកសារថ្មីនីមួយៗដែលលោកបានពិនិត្យមើលដោយខ្លួនលោកផ្ទាល់ (ហាក់ដូចជាខ្លួនគាត់ផ្ទាល់ជាអ្នកធានាបាននូវយថាភូតនៃឯកសារទាំងនោះយ៉ាងដូច្នោះ) សម្រាប់រូបលោក វាដូចជា "ការស្រស់ស្រូបអាហារពេលព្រឹក"[8] ដ៏ឆ្ងាញ់ពិសាមួយ គាត់មានការចាប់អារម្មណ៍ចំពោះពណ៌ និងគុណភាពក្រដាសរបស់ឯកសារ ឬក៏កាលបរិច្ឆេទដែលមាននៅក្នុងឯកសារ និងវាក្យសព្ទដែលបានប្រើប្រាស់នៅក្នុងឯកសារនោះ[9]។

---

[5] ប្រតិចារឹកសវនាការ ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២ អត្ថបទប្រតិចារឹកព្រាង ទំព័រ ១៣ បន្ទាត់ ២៣-២៥ [លេខទំព័រ និងលេខបន្ទាត់ក្នុងប្រតិចារឹកជាភាសាបារាំង]។

[6] ប្រតិចារឹកសវនាការ ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១២ អត្ថបទប្រតិចារឹកព្រាង ទំព័រ ៣៤-៣៥ [លេខទំព័រ និងលេខបន្ទាត់ក្នុងប្រតិចារឹកជាភាសាបារាំង]។

[7] ប្រតិចារឹកសវនាការ ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២ អត្ថបទប្រតិចារឹកព្រាង ទំព័រ ៩ [លេខទំព័រ និងលេខបន្ទាត់ក្នុងប្រតិចារឹកជាភាសាបារាំង]។

[8] ប្រតិចារឹកសវនាការ ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២ អត្ថបទប្រតិចារឹកព្រាង ទំព័រ ៣២ បន្ទាត់ ៦-៧ និងទំព័រ ៥៣ បន្ទាត់ ១០-១១ [លេខទំព័រ និងលេខបន្ទាត់ក្នុងប្រតិចារឹកជាភាសាបារាំង]។

[9] ប្រតិចារឹកសវនាការ ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១២ អត្ថបទប្រតិចារឹកព្រាង ទំព័រ ៣៥-៣៦។

នៅពេលដែលពណ៌ និងគុណភាពក្រដាសរបស់ឯកសារមិនអាចពិនិត្យបញ្ជាក់បានចេញពីឯកសារថតចម្លង ហើយកាលបរិច្ឆេទ និងវាក្យសព្ទដែលបានប្រើប្រាស់នៅក្នុងឯកសារនឹងពិតជាអាចធ្វើត្រាប់តាមបានដោយអ្នកក្លែងឯកសារ ហើយដែលមិនមានអាជ្ញាធរតុលាការរបស់ អ.វ.ត.ក ណាមួយបានពិនិត្យបញ្ជាក់អំពីបញ្ហានេះរហូតមកទល់នឹងពេលបច្ចុប្បន្ននេះ វាជាការជៀសមិនផុតទេដែលយ៉ាងហោចណាស់តុលាការត្រូវតែធានាថា រាល់ឯកសារខាងលើនេះត្រូវបានគេប្រគល់ជូនតុលាការ។

៧. តាមរយៈសំណើសុំនេះ លោក ខៀវ សំផន សូមនិយាយម្តងហើយម្តងទៀតអំពីភាពមន្ទិលសង្ស័យរបស់គាត់ចំពោះភាពអាចជឿទុកចិត្តបាន និងយថាភូតនៃឯកសារដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា។ តាមយោបល់គាត់ នៅពេលដែលឯកសារដែលត្រូវបានប្រើប្រាស់នៅក្នុងសំណុំរឿងមានទម្រង់ជាឯកសារដែលត្រូវបានគេអះអាងថាជាឯកសារដើម ឬគ្រាន់តែមានទម្រង់ជាឯកសារថតចម្លង ឬក៏ឯកសារចម្លងចេញពីឯកសារចម្លងនោះ ចៅក្រម និងភាគីនានាត្រូវតែទទួលបាននូវការជូនដំណឹងអំពីរឿងនេះ។ លើសពីនេះទៅទៀតនោះ រាល់ឯកសារទាំងអស់ដែលជាច្បាប់ដើម ត្រូវតែអាចយកមកប្រើប្រាស់បានភ្លាមៗ ដើម្បីប្រគល់ជូនចៅក្រម និងភាគីនានានៅក្នុងពេលសវនាការ។

៨. ដូចដែលគាត់បានស្នើសុំរួចមកហើយកាលពីខែមេសា ឆ្នាំ២០១១ លោក ខៀវ សំផន បានសុំដល់អង្គជំនុំជម្រះសាលាដំបូងឲ្យបង្គាប់ថា គេត្រូវតែបង្ហាញគាត់ នូវរាល់ឯកសារដែលបានប្រកាសថា ជាឯកសារច្បាប់ដើម[10]។ យ៉ាងហោចណាស់ក៏គួរតែបំពេញតាមសំណូមពរនេះដែរ ព្រោះថានៅក្នុងអំឡុងពេលនៃការស៊ើបអង្កេត ពុំមានឯកសារណាមួយត្រូវបានផ្តល់ជូនដល់ជនត្រូវចោទជាទូទៅឡើយ ហើយជាពិសេសនោះគឺលោក ខៀវ សំផន[11]។

៩. លើសពីនេះទៅទៀតនោះ វិធានការមួយបែបនេះគឺមានលក្ខណៈងាយស្រួលធ្វើ ដោយហេតុថា លោក ឆាំង យុ បានបញ្ជាក់ប្រាប់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវការរយៈពេលចំនួនតែ "មួយខែ" ប៉ុណ្ណោះ ដើម្បីបញ្ជូនមកតុលាការ នូវឯកសារសម័យនោះដែលមជ្ឈមណ្ឌលគិតថាខ្លួនមាន[12]។

---

[10] បញ្ជីឯកសារ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ ឯកសារ **E9/29** កថាខណ្ឌ ១៧-១៨ និង កថាខណ្ឌ ២២។

[11] គឺមានតែនៅក្នុងពេលមួយនៃការសួរចម្លើយលោក ខៀវ សំផន ប៉ុណ្ណោះ ដែលឯកសារមួយ (កំណត់ហេតុនៃការប្រជុំ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥) ត្រូវបានលើកឡើងដោយសហព្រះរាជអាជ្ញាជាតិ ដែលសហព្រះរាជអាជ្ញាជាតិ មិនទាំងបានបង្ហាញឯកសារនោះ ជាសំណៅដើម ឬក្រោមទម្រង់ជាឯកសារថតចម្លង ដល់លោក ខៀវ សំផន ឡើយ៖ កំណត់ហេតុនៃការសួរចម្លើយ ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៧ ឯកសារ **D47** ឬ **E3/37** ទំព័រ ៤ [លេខទំព័រអត្ថបទភាសាបារាំង]។

[12] ប្រតិចារឹកសវនាការ ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២ អត្ថបទប្រតិចារឹកព្រាង ទំព័រ ៣២ បន្ទាត់ ១៤-២៥ [លេខទំព័រ និងលេខបន្ទាត់ក្នុងប្រតិចារឹកជាភាសាបារាំង]; លោក ឆាំង យុ ធ្លាប់បានជម្រាបសហព្រះរាជអាជ្ញាថា រាល់សំណៅដើមនៃឯកសារដែលមជ្ឈមណ្ឌលរបស់លោកមាន **ទោះជាឯកសារទាំងនោះនៅក្នុងប្រទេសកម្ពុជា ឬក៏នៅបរទេសក៏ដោយ** គឺអាចរកបាន

## II. កិច្ចពិភាក្សា

១០. វិធាន ៨៧.២ នៃវិធានផ្ទៃក្នុងចែងថា "*សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវផ្អែកលើភស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយដែលភស្តុតាងនោះត្រូវផ្តងកាត់ការដេញដោល*" ។

១១. នៅក្នុងសំណុំរឿង ឌុច អង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់ថា "*នៅពេលដែលសម្ភារៈត្រូវបានដាក់បង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ តម្លៃដាក់បន្ទុកនៃភស្តុតាងនេះ និងការថ្លឹងថ្លែងដើម្បីឱ្យមានការយល់ស្របទៅនឹងភស្តុតាងនោះ នឹងត្រូវបានធ្វើការវាយតម្លៃដោយអង្គជំនុំជម្រះ*"។[13]

១២. នៅក្នុងរឿងក្តីដដែលនេះ អង្គជំនុំជម្រះសាលាដំបូងបានសុំឱ្យសហព្រះរាជអាជ្ញា ផ្តល់នូវឯកសារច្បាប់ដើម នៃឯកសារដែល សហព្រះរាជអាជ្ញា មានបំណងបញ្ចូលទៅក្នុងការពិភាក្សា បន្ទាប់ពីបានប្រកាសថា "*ដើម្បីជួយដល់អង្គជំនុំជម្រះដើម្បីសម្រេចយថាភាពនៃឯកសារ អង្គជំនុំជម្រះត្រូវពិចារណាលើភស្តុតាងទាំងអស់ ដែលអាចមានភាពពាក់ព័ន្ធទៅនឹងបញ្ហានេះ*"។[14]

១៣. មានទំនោរទៅរកការប្រើប្រាស់ឯកសារច្បាប់ដើមជាងឯកសារដ៏ទៃ នៅក្នុងតុលាការ ad hoc ដែល "ផ្អែកទៅលើភស្តុតាងល្អលើសគេ ដែលមាននៅក្នុងកាលៈទេសៈពិសេសនោះ"។[15] ជាឧទាហរណ៍ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា ចាត់ទុកថា ៖

"*ច្បាប់ដើមនៃឯកសារណាមួយ មិនមែនជាលក្ខខណ្ឌចាំបាច់ដំបូងដែលនាំឱ្យមានការយល់ព្រមយកឯកសារនោះ ទៅប្រើប្រាស់ជាភស្តុតាងនោះឡើយ ប៉ុន្តែនៅក្នុងករណីមានឯកសារនោះមាន អង្គជំនុំ*

---

ប្រសិនបើមានការស្នើសុំពីតុលាការ៖ កំណត់ហេតុនៃការសួរចម្លើយ ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៧ ឯកសារ **23.3 ទំព័រ ៤** (ERN 00141849) [លេខទំព័រក្នុងអត្ថបទជាភាសាបារាំង]។

[13] សំណុំរឿង ០០១ សេចក្តីសម្រេចអំពីភាពអាចទទួលយកសម្ភារៈដែលមាននៅក្នុងសំណុំរឿងធ្វើជាភស្តុតាង ថ្ងៃទី២៦ ខែឧសភា ឆ្នាំ ២០០៩ ឯកសារ E43/4 កថាខណ្ឌទី៧។

[14] សំណុំរឿង ០០១ សេចក្តីសម្រេចអំពីភាពអាចទទួលយកបាននៃភស្តុតាងថ្មី និងសេចក្តីណែនាំដល់ភាគីទាំងអស់ ថ្ងៃទី១០ ខែមិនា ឆ្នាំ ២០០៩ ឯកសារ D288/6.5/10/2 កថាខណ្ឌទី៨។

[15] រឿងក្តី រដ្ឋអាជ្ញា តទល់នឹង *Hadzihasanovic និងបក្ខពួក* ឯកសារ IT-01-47-T សេចក្តីសម្រេចទាក់ទងទៅនឹងការទទួលយកឯកសារពីមេធាវីការពារក្តីរបស់លោក Hadzihasanovic ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៥ កថាខណ្ឌទី១៥ ។ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង *Perisic* ឯកសារ IT-04-81-T *Order for Guidelines on the Admission and Presentation of Evidence and Conduct of Cousel in Court* ថ្ងៃទី២៩ ខែតុលា ឆ្នាំ ២០០៨ កថាខណ្ឌទី៣៥-៣៦។

*ជម្រះចង់ទទួលបានឯកសារច្បាប់ដើម ដើម្បីធ្វើយ៉ាងណាអាចឲ្យភាគីធ្វើការវាយតម្លៃទៅលើយថាភូត នៃឯកសារនោះបាន*"។[16]

១៤. ដូចប្រសាសន៍របស់លោកប្រធាន អង្គជំនុំជម្រះដូច្នោះដែរ "*ឯកសារនានាគឺជាផ្នែកមួយដ៏សំខាន់នៃភស្តុតាងនៃសំណុំរឿង ០០២*"។[17] ព្រមទាំងសេចក្តីអះអាងរបស់លោកចៅក្រម LAVERGNE ផងដែរដែលថា "*អ្វីដែលយើងចង់ដឹងគឺថា តម្លៃនៃឯកសារទាំងអស់នេះ នៅក្នុងការពិភាក្សាដេញដោលរបស់យើង*"។[18]

១៥. តម្លៃគួរឲ្យជឿជាក់បាននៃឯកសារអាស្រ័យដោយផ្ទាល់ទៅ នឹងយថាភូតរបស់វា។ ហេតុដូច្នេះហើយ អ្វីដែលគេចាត់ទុកថាមានយថាភូតកាលពីសម័យកាលនោះ តាមរយៈអង្គការមួយដែលមិនមានលក្ខណៈជាស្ថាប័នតុលាការ ហើយដែលគេយកទៅប្រើប្រាស់ធ្វើជាមូលដ្ឋាននៃការចោទប្រកាន់ ដាច់ខាតត្រូវតែនាំយកឯកសារនោះមកកាន់សាលសវនាការ ដើម្បីឲ្យចៅក្រម និងភាគីអាចពិនិត្យ នៅក្នុងក្របខណ្ឌនៃការពិភាក្សាដេញដោលគ្នាជាសាធារណៈ។

១៦. ដោយអនុលោមទៅតាមវិធានផ្ទៃក្នុងដែលអនុវត្តនៅចំពោះមុខ អ.វ.ត.ក តាមយុត្តិសាស្ត្រនៃតុលាការនេះ តាមយុត្តិសាស្ត្រនៃតុលាការព្រហ្មទណ្ឌអន្តរជាតិនានា និងដោយសារទាំងព្រះរាជអាជ្ញា ឬចៅក្រមស៊ើបអង្កេតណាម្នាក់មិនបានឃើញឯកសារទាំងនោះ ឯកសារចម្លងចេញពីឯកសារចម្លងរួចម្តងហើយដែលដែលគេគិតថាធ្វើឡើងពីសម័យកាលនោះ នឹងមិនមានតម្លៃគួរឲ្យជឿជាក់ទេ ហើយចៅក្រមក៏ពុំអាចផ្តល់នូវទម្ងន់ដល់ឯកសារទាំងនោះឡើយ។

## អាស្រ័យហេតុនេះ

១៧. ក្រុមមេធាវីការពារក្តីរបស់លោក ខៀវ សំផន ស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូង មេត្តា ៖

---

[16] រឿងក្តី រដ្ឋអាជ្ញា តទល់នឹង . *Bagosora និងបក្ខពួក* ឯកសារ ICTR-98-41-T សេចក្តីសម្រេចទាក់ទងទៅនឹងសំណើសុំរបស់រដ្ឋអាជ្ញាក្រោមចំណងជើងថា *Prosecutor's Motion for the Admission of Certain Materials under Rule 89 (C) of the Rules of Procedure and Evidence* ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៤ កថាខណ្ឌទី២៥ ។

[17] ប្រតិចារឹកនៃសវនាការ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២ ឯកសារតុលាការ E1/27.1 ទំព័រ២ បន្ទាត់ ៥-៦ [លេខទំព័រក្នុងអត្ថបទជាភាសាបារាំង]

[18] ប្រតិចារឹកនៃសវនាការ ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១២ អត្ថបទប្រតិចារឹកព្រាង ទំព័រ ៨ បន្ទាត់ ៥-៦ [លេខទំព័រក្នុងអត្ថបទជាភាសាបារាំង]

- ធានាឲ្យបានពីចំនួនពិតប្រាកដនៃឯកសារនៅក្នុងសំណុំរឿង ឬដែលភាគីចង់បាន ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាមាន ហើយដែលចាត់ទុកថាជាឯកសារពីសម័យកាលនោះ

- បង្គាប់ឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជានាំយកនូវឯកសារដែលគេសន្មតថាជាឯកសារដើមទាំងនោះមកកាន់តុលាការ

- បង្គាប់ថា ចំពោះឯកសារនិមួយៗដែលអង្គជំនុំជម្រះចាត់ទុកថា ជាឯកសារដើមនាសម័យកាលនោះ និងដែលផ្តល់មកតុលាការនោះ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏នឹងផ្តល់មកជាមួយនូវព័ត៌មានលម្អិតអំពីខ្សែសង្វាក់នៃការរក្សាទុកនូវឯកសារដែលខ្លួនមានផងដែរ

- បង្ហាញឯកសារខាងលើនោះនៅក្នុងសវនាការ ហើយអនុញ្ញាតឲ្យភាគីពិនិត្យមើលបាន។

| | | | |
|---|---|---|---|
| | លោកមេធាវី គង់ សំអុន<br>លោកមេធាវី Arthur VERCKEN<br>លោកមេធាវី Jacques VERGÈS | ភ្នំពេញ<br>ប៉ារីស<br>ប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |